www.xtrapapers.com



Diploma Programme
Programme du diplôme
Programa del Diploma

# Khmer A: literature – Higher level – Paper 1
# Khmer A : littérature – Niveau supérieur – Épreuve 1
# Khmer A: literatura – Nivel superior – Prueba 1

Friday 8 May 2015 (afternoon)
Vendredi 8 mai 2015 (après-midi)
Viernes 8 de mayo de 2015 (tarde)

2 hours / 2 heures / 2 horas

---

### Instructions to candidates

- Do not open this examination paper until instructed to do so.
- Write a literary commentary on one passage only.
- The maximum mark for this examination paper is **[20 marks]**.

### Instructions destinées aux candidats

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire littéraire sur un seul des passages.
- Le nombre maximum de points pour cette épreuve d'examen est de **[20 points]**.

### Instrucciones para los alumnos

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario literario sobre un solo pasaje.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2215–0565



© International Baccalaureate Organization 2015

International Baccalaureate
Baccalauréat International
Bachillerato Internacional

www.xtrapapers.com



សូមអ្នកសរសេរអត្ថាធិប្បាយបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ៖

1.

ព្រះប្រជាភិបាល ស្ដេចផ្ទៀងព្រះនេត្រទតទៅក្រៅព្រះរាជដំណាក់ដោយទឹកព្រះភក្ត្រាបស្មើ ក្នុងព្រះទ័យនៅព្រួយបារម្ភជាប់ជានិច្ចព្រោះមិនទាន់ស្គាល់មន្ត្រីក្បថជាអ្នកណា ។

-ខ្ញុំព្រួយបារម្ភដល់វាសនានៃប្រទេសជាតិរបស់ខ្ញុំណាស់ លោកតាហោរា! (ព្រះអង្គមានបន្ទូលក្រោយពីបែរព្រះភក្ត្រមកវិញ) បើក្នុងព្រះនគរមានមន្ត្រីក្បថ រាស្ត្រប្រជារបស់ខ្ញុំប្រាកដជាគ្មានសេចក្ដីសុខ ។

លោកតាហោរាស្ដាប់ព្រះបន្ទូលប្រកបទៅដោយព្រះទ័យស្នេហារាស្ត្ររបស់ព្រះមហាក្សត្រ គាត់ក៏ធ្លាក់ទឹកមុខក្រៀមស្រពោន ជួយនឹកព្រួយទៅដល់វាសនាប្រទេសជាតិក្នុងពេលអនាគត ។

........................................................................................................................................

ប្រាំពីរទិវាក្រោយមកព្រះបាទសុរិយាវង្ស៍ទី២ព្រះអង្គក៏ទ្រង់ចាត់ឱ្យសេនាទាហាន ព្រមទាំងប្រជារាស្ត្រស្ម័គ្រចិត្តកសាងប្រាសាទកំពូលប្រាំ ១ ស្ថិតនៅទិសទក្សិណ ចម្ងាយពីព្រះបរមរាជវាំងមហានគរ បីរយសិន ។

ក្នុងការស្ថាបនានេះ មានចៅហ្វាសូរជាមេជាង ចំណែកលោកសេនានុពន្ធឃោសៈ បុរោហិតបុល លោកពិជ័យសង្គ្រាម និងពលរិទ្ធ ជាអ្នកចាំមើលការខុសត្រូវទៅលើកម្មករស្ម័គ្រចិត្ត ។ ការកសាងប្រាសាទកំពលប្រាំចេះតែមានល្បឿនជឿនលឿនទៅមុខជាលំដាប់ ។ ក្នុងពេលជាមួយគ្នានេះ អំពើចោរកម្មដែលបាត់ស្ងាត់អស់មួយខណៈ ក៏ចាប់ផ្ដើមមានសកម្មភាពជាថ្មី ហើយខ្លាំងក្លាជាងលើកមុនៗទាំងអស់ ។

ប្រជារាស្ត្រមានសេចក្ដីក្ដៅក្រហាយ ។ គ្រប់និគមជនបទឮសូរតែអំពើចោរកម្មរៀងរាល់ថ្ងៃ ។ ព្រះចមចក្រទ្រង់ញាប់ញ័រព្រះសញ្ញីកើតក្ដីព្រួយបារម្ភគ្មានពេលល្ហែ ។

ព្រឹកមួយ ព្រះរាជាស្ដេចបានត្រាស់ហៅសព្វមុខនាម៉ឺនមន្ត្រី មកពិភាក្សាពីរឿងភ័យវិបត្តិក្នុងព្រះនគរ ។ ក្នុងឱកាសនោះគេឃើញ លោកចៅហ្វាសូរ, បុរោហិតបុល, ព្រះអង្គម្ចាស់ព្រះឧបរាជ, សេនានុពន្ធឃោសៈ, លោកមេទ័ពពិជ័យសង្គ្រាម, សញ្ជ័យ, ពលរិទ្ធ និងឧកញ៉ាមហាគង់ ក្រាបបង្គំគាល់ព្រះចក្រី ដោយសភាពស្ងប់ស្ងាត់ ។

ព្រះមហាក្សត្រ ទ្រង់ថ្លែងព្រះសង្កថាយ៉ាងវែង ស្ដីពីភ័យវិបត្តិដែលកំពុងកើតមាននៅគ្រប់ភូមិស្រុកក្នុងព្រះនគរ បណ្ដាលឱ្យប្រជារាស្ត្រមានសេចក្ដីក្ដៅក្រហាយ កើតទុក្ខវេទនា ព្រោះតែអំពើយង់ឃ្នង កាច សាហាវរបស់ចោរព្រៃ សឹងពុំមានកងទាហានជាតិខាងក្រុមណា ទៅបង្ក្រាបបានសោះ ។ ទីបំផុត ព្រះអង្គបានអំពាវនាវអស់លោកមេទ័ព ព្រមទាំងសព្វមុខមន្ត្រី ឱ្យរួបរួមចងបាច់សាមគ្គីជាធ្លុងមួយ ដើម្បីបង្ក្រាបពួកខ្មាំង ។ ព្រះអង្គបានសុំឱ្យសមាជិកនៃអង្គប្រជុំ បញ្ចេញយោបល់របស់ខ្លួនម្នាក់មួយ នៅពេលដែលគេគិតឃើញឱ្យទូលតបមកព្រះអង្គវិញ ។

ក្នុងខណៈដែលនាម៉ឺនសព្វមុខមន្ត្រី កំពុងនឹកគឺតរកយោបល់ថ្វាយទៅព្រះរាជា ក៏ស្រាប់តែលេចនាយកងពាលលក្ខណ៍ សេនាជំនិតរបស់សេនានុពន្ធឃោសៈ ចងច្រវ៉ាក់អ្នកទោសម្នាក់ មានស្នាមរបួសបែកឈាមពេញខ្លួន ដឹកចូលមកចំពោះព្រះភក្ត្រព្រះអង្គ ។

នាយពាលលក្ខណ៍ក្រាបបង្គំទូលទៅព្រះនរនាថ កណ្ដាលចំណោមមន្ត្រី ដែលកំពុងផ្ដោតចក្ខុមើលមកខ្លួនគេគ្រប់ៗគ្នា ដោយសេចក្ដីងឿងឆ្ងល់ថា ៖

-សូមក្រាបទូលព្រះសម្មតិទេព ជាអម្ចាស់ជីវិតលើត្បូង អ្នកទោសនេះគឺខ្មាំងដែលទូលព្រះបង្គំចាប់បានកាលពីព្រឹកមិញ ក្នុងខណៈដែលវាកំពុងប្រព្រឹត្តអំពើចោរកម្មជាមួយបក្សពួកក្នុងភូមិ ក្រាបទូល!

នាយកងពាលលក្ខណ៍ ងាកទៅមើលមុខលោកមេទ័ពពិជ័យសង្គ្រាម និងពលរិទ្ធបន្តិចទើបទូលព្រះករុណាតទៅទៀត ៖

www.xtrapapers.com



-អ្នកទោសនេះ ទូលបង្គំបានវាយធ្វើទារុណកម្មវាជាច្រើន ដើម្បីសួររកចម្លើយរកមេកើយរបស់វា ទីបំផុតវាឆ្លើយប្រាប់ទូលបង្គំថា ពួកវាព្រមទាំងរូបវានេះ បានទទួលបញ្ជាពីលោកមេទ័ពពិជ័យសង្គ្រាម និងលោកមេទ័ពរងពលរិទ្ធ ឱ្យដើរកាប់សម្លាប់ ប្លន់ដុតផ្ទះអ្នកស្រុក ទូលបង្គំសូមយកវាមកថ្វាយចំពោះព្រះអង្គ សូមព្រះអង្គសាកសួរវាដោយផ្ទាល់ចុះ!...

លោកពិជ័យសង្គ្រាម និងពលរិទ្ធ មិននឹកស្មានថាគ្រោះអាក្រក់នឹងធ្លាក់មកដល់ខ្លួនដោយចៃដន្យ ដូច្នេះ ក៏រន្ធត់តក់ស្លុតឥតឧបមា មុនដែលអ្នករងគ្រោះដោយអំពើព្យាបាទទាំងពីរថ្លាថ្លែងអ្វី ព្រះប្រជាភិបាលក៏មានបន្ទូលខ្លាំងៗ ប្រកបដោយទឹកព្រះភក្ត្រក្រេវក្រោធមហិមាថា ៖

-ហ្នឹងហើយឬ សេចក្តីស្មោះត្រង់ស្នេហាជាតិរបស់លោកពិជ័យសង្គ្រាម និងពលរិទ្ធ? នែ! មើលអ្នកឯងនិយាយប្រាប់យើងឱ្យត្រង់មកមើល លោកពិជ័យសង្គ្រាមប្រើឱ្យទៅប្រព្រឹត្តអំពើចោរកម្ម ដូចពាក្យសេនាមាត្រថាអំបាញ់មិញមែនឬ?

ព្រះអង្គត្រាស់សួរអ្នកទោស ។

-សូមទ្រង់ព្រះមេត្តាប្រោស!... លោកពិជ័យសង្គ្រាម និងលោកពលរិទ្ធ ប្រើឱ្យទូលបង្គំប្រព្រឹត្តអំពើចោរកម្មមែនក្រាបទូល បើល្អងធូលីព្រះបាទនៅសង្ស័យ ទូលបង្គំសូមថ្វាយលិខិតលោកពិជ័យសង្គ្រាម ជាតឹកតាង...!

ថាហើយ អ្នកទោសក្លែងក្លាយក៏ថ្វាយលិខិត ដែលក្តាប់ជាប់ក្នុងដៃទៅព្រះចមភព ។

ព្រះអង្គទ្រង់ទតលិខិតអ្នកទោសថ្វាយ ដែលសំអាងថាជាលិខិតរបស់លោកពិជ័យសង្គ្រាមដោយព្រះទ័យមួហ្មង ។

ទតចប់កាលណា ព្រះអង្គក៏ញ័រញាក់សព្វព្រះឥន្ទ្រីយ៍ ។ ក្រេវក្រោធខ្លាំងណាស់! ព្រះអង្គជឿជាក់ថាលោកពិជ័យសង្គ្រាម និងបុត្រក្បថចំពោះព្រះរាជបល្លង្កជាពិតប្រាកដ ។

-លោកពិជ័យសង្គ្រាម! លោក និងបុត្រជាមនុស្សក្បថ! ទោសរបស់លោកត្រូវតែប្រហារជីវិត! ឥឡូវលោកមានពាក្យដោះស្រាយយ៉ាងដូចម្តេច?

លោកពិជ័យសង្គ្រាម និងបុត្រនៅស្ងៀម មិនព្រមឆ្លើយតប ព្រោះបើលោកជជែកវែកញែក នៅពេលដែលព្រះអង្គទ្រង់ព្រះពិរោធខ្លាំងដូច្នេះ ក៏ជាការអត់ប្រយោជន៍ ។ សេនានុពន្ធឃោសៈ បុរោហិតបុល ឧកញ៉ាមហាគង់ព្រមទាំងមន្ត្រីឯទៀត នាំគ្នាមើលមកអ្នករងគ្រោះទាំងពីរ ដោយក្រសែភ្នែកខ្ពើមរអើម មានតែលោកចៅហ្វាសួរមួយទេ ដែលនឹកអាណិតលោកពិជ័យសង្គ្រាមដោយមិនទាន់ជឿថាក្បថ ។

ព្រះចមពង្ស កាលបើឃើញលោកពិជ័យសង្គ្រាម និងពលរិទ្ធនៅស្ងាត់ស្ងៀមជាទំនងទទួលសារភាព ព្រះអង្គក៏កាន់តែខ្ញាល់ ត្រាស់បង្គាប់ទៅលោកសេនានុពន្ធថា ៖

-លោកឃោសៈ! លោកនាំមនុស្សក្បថទាំងពីរ ទាំងបីនាក់នេះទៅឃុំឃាំងសិនទៅ កុំឱ្យនៅនឹងមុខនឹងមាត់ខ្ញុំដូច្នេះទៀត!

មានព្រះបន្ទូលចប់ហើយ ព្រះអង្គក៏យាងចេញពីរោងជំនុំ សំដៅព្រះដំណាក់បង្អាក់ការប្រជុំតែត្រឹមណោះ ។

ហាក់ ឆៃហុក, *ក្រោមម្លប់អង្គរ* (២០០២)

www.xtrapapers.com



**2.**

### ហៅហ៊ាន ហៅចេះ

ខ្លួនខុសកុំកែយករួចខ្លួន　　រ៉ាប់រងឱ្យធ្ងន់ត្រូវហ៊ានរ៉ាប់
យ៉ាប់ឈប់ធ្វើខុសទើបឈប់យ៉ាប់　　មើលក្បួនមើលច្បាប់ខំប្រឹងមើល ។
ហ៊ានថាហ៊ានធ្វើទើបហៅហ៊ាន　　ធ្វើទាំងបំពានចូរខំធ្វើ
ស្មើរធ្វើឱ្យស្មាក់នឹងលែងស្មើរ　　បើធ្វើទាំងល្ងើមិនគ្រាន់បើ ។
ការដែលត្រូវធ្វើត្រូវមើលការណ៍　　ប្រើនូវប្រាជ្ញាតោងរៀនប្រើ
ដើរ, ដេក, អង្គុយ, ឈរ, រៀនដើរ　　កិច្ចកលដំណើរសុទ្ធមានកិច្ច ។
គិតគូររឿងជាតិត្រូវជួយគិត　　តិចផ្ដុំគំនិតច្រើនលែងតិច
ល្បិចត្រូវសាកល្បងទើបលែងស្គាល់ល្បិច　　ប្រាប់នូវហេតុម្ដេចដែលគួរប្រាប់ ។
ថាអ្វីគិតសិនសឹមស្ដីថា　　ច្បាប់ច្រើនបានការតោងពឹងច្បាប់
ស្លាប់ខ្លួនតែឈ្មោះរស់មិនស្លាប់　　អាចឱ្យគេគ្រាប់តាមដែលអាច ។
ស្លូតនឹងអ្នកជាទើបហៅស្លូត　　កាចកុំរហូតទើបហៅកាច
ខ្លាចគេបើចង់ឱ្យគេខ្លាច　　អួតអាងអំណាចចូរកុំអួត ។
ល្អគេគោរពព្រោះយើងល្អ　　ឆ្កួតខ្មៅជាសចូរកុំឆ្កួត
ព្រួតខាំអ្នកជាចូរកុំព្រួត　　ប្រឹងអត់អំណួតដោយខំប្រឹង ។
គេជេរចូរគិតដល់ពាក្យគេ　　ខឹងកែល្អទ្វេទើបហៅខឹង
ដឹងហេតុនិងផលប្រាជ្ញហៅដឹង　　ចេះច្បាស់ប៉ុណ្ណឹងប្រាជ្ញហៅចេះ ។
យកពាក្យគេគិតល្អរើសយក　　ផេះផងកុំភ្នកបើមិនផេះ
សេះដាច់គេតែងតាមដោយសេះ　　ខ្សោយងាយរបេះត្បិតខ្លួនខ្សោយ ។
តាកាន់តែចាស់ហើយចៅតា　　ក្រោយគង់មរណានៅថ្ងៃក្រោយ
ដោយចាស់ទើបមិនចង់បណ្ដោយ　　ចេះពាក្យតាឱ្យនេះហៅចេះ ។

ខឿន សាឃាង, *មកដល់ស្រុកវិញ* (២០០៨)